ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០២៣ អបស.ប្រជង

ថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៨.

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ជំរាបមក

## លោក-លោកស្រីប្រធានមន្ទីរសុខាភិបាលរាជធានី -ខេត្ត

**កម្មវត្ថុ ៖** វគ្គបណ្តុះបណ្តាលអេពីដេមីសាស្ត្រអនុវត្តឆ្នាំ ២០១៨ រយៈពេល៤សប្តាហ៍សម្រាប់មន្ត្រីនៃមន្ទីរសុខាភិបាលស្រុកប្រតិបត្តិរាជធានី-ខេត្ត បំពេញការងារទាក់ទងនឹងប្រព័ន្ធតាមដានជំងឺឆ្លង។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោក-លោកស្រីប្រធានថា៖ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង រួមសហការជាមួយនឹងអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជានឹងរៀបចំវគ្គបណ្តុះ បណ្តាល អេពីដេមីសាស្ត្រអនុវត្តជំនាន់ទី ៨ រយៈពេល ៤សប្តាហ៍ សម្រាប់ឆ្នាំ ២០១៨ ខាងមុខនេះ។ វគ្គនេះមានគោលបំណងអភិវឌ្ឍចំណេះដឹងជំនាញសមស្រប និងពង្រឹងសមត្ថភាពមន្ត្រីនៃមន្ទីរសុខាភិបាលស្រុកប្រតិបត្តិ រាជធានីខេត្តដែលបំពេញការងារទាក់ទងនឹងប្រព័ន្ធតាមដានជំងឺក្នុងតំបន់ទទួលខុសត្រូវរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងការផ្ទុះការរាតត្បាតជំងឺ។ វគ្គសិក្សានេះចែកចេញជា២តំណាក់កាល៖ <u>តំណាក់កាលទី ១</u> : ចាប់ផ្តើម ពីថ្ងៃទី ១២ ខែមិនា ដល់ថ្ងៃទី ២៣ ខែមិនា ឆ្នាំ ២០១៨ និង<u>តំណាក់កាលទី ២</u> : ចាប់ផ្តើមពីថ្ងៃទី ០២ ខែមេសា ដល់ថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៨។ ការទទួលពាក្យសុំចូលរៀននឹងចាប់ផ្តើមពីថ្ងៃផ្សព្វផ្សាយនេះ រហូតដល់ថ្ងៃទី ០៥ ខែមិនា ឆ្នាំ២០១៨ ម៉ោង ០៥ រសៀល ។ លេខាធិការដ្ឋាននៃវគ្គអេពីដេមីសាស្ត្រនឹងជូនដំណឹង ដល់សិក្ខាកាមដែលត្រូវបានជ្រើសរើសឲ្យចូលសិក្សា វគ្គសិក្សាអេពីដេមីសាស្ត្រថ្នាក់មូលដ្ឋាន (AET Introductory course) ។ សិក្ខាកាមចំនួន ៣-៥នាក់ ដែលបញ្ចប់វគ្គសិក្សាអេពីដេមីសាស្ត្រថ្នាក់មូលដ្ឋានដោយជោគជ័យ នឹងត្រូវបានជ្រើសរើសឲ្យចូលសិក្សាបន្តក្នុងវគ្គសិក្សាអេពីដេមីសាស្ត្រ អនុវត្តរយៈពេលប្រាំមួយខែ (Foundation Course)។

រាល់ការចំណាយក្នុងការបណ្តុះបណ្តាលជាបន្ទុករបស់អង្គការសុខភាពពិភពលោក។

ពាក្យសុំចូលរៀន និងព័ត៌មានផ្សេងៗសូមបើកមើល website របស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង (www.cdcmoh.gov.kh) និងតាមរយៈបណ្តាញសង្គមFacebook(<u>https://www.facebook.com/pages/ Cambodian-Applied-Epidemiology-Training-AET</u>)

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធានជួយផ្សព្វផ្សាយ និងលើកទឹកចិត្តមន្ត្រីក្រោមឱវាទ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យដាក់ពាក្យសុំចូលរៀនក្នុងវគ្គនេះកុំបីអាក់ខានឡើយ។

សូមលោក លោកស្រីប្រធានទទួលនូវការរាប់អានអំពីខ្ញុំ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង_ហួត

# ក្រសួងសុខាភិបាល
# វគ្គបណ្តុះបណ្តាលអេពីដេមីសាស្រ្តអនុវត្តនៅកម្ពុជា

នាយកដ្ឋានប្រយុទ្ធនឹងជម្ងឺឆ្លងនៃក្រសួងសុខាភិបាលសហការជាមួយអង្គការសុខភាពពិភពលោកនឹងរៀបចំវគ្គបណ្តុះបណ្តាលអេពីដេមីសាស្រ្តអនុវត្ត ស្តីពីការតាមដាន និងឆ្លើយតបចំពោះការរាតត្បាត **ជំនាន់ទីប្រាំបី** ដែលនឹងប្រព្រឹត្តទៅនៅនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាល។ វគ្គសិក្សានេះចែកចេញជាពីរតំណាក់កាលៈ **តំណាក់កាលទី១** ចាប់ផ្តើមពីថ្ងៃទី ១២ ខែមិនា ដល់ថ្ងៃទី ២៣ ខែមិនា ឆ្នាំ ២០១៨ និង**តំណាក់កាលទី២** ចាប់ផ្តើមពីថ្ងៃទី ០២ ខែមេសា ដល់ថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៨។ ការទទួលពាក្យសុំចូលរៀននឹងចាប់ផ្តើមពីថ្ងៃផ្សព្វផ្សាយនេះ រហូតដល់ថ្ងៃទី **០៥ ខែមិនា ឆ្នាំ២០១៨** ម៉ោង ០៥ រសៀល។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងផ្តល់អោយសិក្ខាកាមនូវចំណេះដឹងនិងជំនាញសមស្របព្រមទាំងឱកាសដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តការតាមដាន និងឆ្លើយតបទៅនឹងការរាតត្បាតអោយមានប្រសិទ្ធិភាពនៅក្នុងប្រទេសកម្ពុជា។

វគ្គបណ្តុះបណ្តាលនេះ នឹងគ្របដណ្តប់ទៅលើមុខវិជ្ជាដូចតទៅៈ

- **ចំណេះដឹងអេពីដេមីសាស្រ្ត** (Epidemiology Concept)
- **ជីវស្ថិតិវិទ្យា** (Biostatistics)
- **ការតាមដានសុខភាពសាធារណៈ** (Public Health Surveillance)
- **ទីពិសោធន៍ និងជីវសុវត្ថិភាព** (Laboratory and Biosafety)
- **ការប្រាស្រ័យទាក់ទងហានិភ័យ** (Risk Communication)
- **ពត៌មានវិទ្យា** (Information Technology)
- **ការបង្ការនិងទប់ស្កាត់ជម្ងឺជាអាទិភាព** (Prevention & Control of Priority Diseases)

សិក្ខាកាមដែលនឹងជ្រើសរើសសម្រាប់វគ្គបណ្តុះបណ្តាលអេពីដេមីសាស្រ្តថ្នាក់មូលដ្ឋាន (AET Introductory Course) ត្រូវសិក្សារយៈពេល៦អាទិត្យ ( ៤សប្តាហ៍សិក្សាក្នុងថ្នាក់និង ២សប្តាហ៍នៅមូលដ្ឋាន) ។ ក្នុងចំណោមសិក្ខាកាមដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលអេពីដេមីសាស្រ្តថ្នាក់មូលដ្ឋាន សិក្ខាកាម ៣-៥នាក់ នឹងត្រូវបានជ្រើសរើសឲ្យសិក្សាបន្ត វគ្គបណ្តុះក្នុងរយៈពេលប្រាំមួយខែ (AET Foundation Course) ។ សិក្ខាកាមនឹងត្រូវស្នាក់នៅក្នុងរាជធានីភ្នំពេញរយៈពេល ៦ខែ ដែលរួមមានការសិក្សាទ្រឹស្តីនៅនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលនិង ចុះប្រមូលទិន្នន័យសម្រាប់គំរោងអេពីដេមីសាស្រ្តចុះអនុវត្តការតាមដាន និងឆ្លើយតបទៅនឹងការរាតត្បាដោយមានការគាំទ្រអំពីក្រុមអ្នកអភិបាលជាតិ និងអន្តរជាតិ។ សិក្ខាកាមនឹងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែក្នុងកំឡុងពេលសិក្សា។ ក្រោយពីបញ្ចប់ការបណ្តុះបណ្តាលមន្រ្តីទាំងនោះត្រូវត្រឡប់ទៅបម្រើ

ការងារនៅអង្គភាពដើមវិញដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដាន និងឆ្លើយតបទៅនឹងការរាតត្បាត។ បុគ្គលិកក្របខ័ណ្ឌរបស់ក្រសួងសុខាភិបាលទាំងឡាយដែលបំពេញលក្ខខ័ណ្ឌតម្រូវដូចខាងក្រោម ត្រូវបានលើកទឹកចិត្តអោយដាក់ពាក្យសុំចូលសិក្សាវគ្គបណ្តុះបណ្តាលនេះ ៖

១-កំពុងបម្រើការងារជាសមាជិកក្រុមឆ្លើយតបបន្ទាន់ នៅថ្នាក់រាជធានី ខេត្ត ឬ ស្រុក ប្រតិបត្តិ មានរយៈពេលយ៉ាងតិចបានមួយឆ្នាំគិតមកដល់ថ្ងៃដាក់ពាក្យ។

២-កំពុងបម្រើការងារទាក់ទងនឹងប្រព័ន្ធតាមដានជំងឺឆ្លងនៅថ្នាក់រាជធានី-ខេត្ត ឬ ស្រុកប្រតិបត្តិ មានរយៈពេលយ៉ាងតិចបានមួយឆ្នាំគិតមកដល់ថ្ងៃដាក់ពាក្យ។

៣-ជាវេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម ឱសថការី ទន្តបណ្ឌិត ទន្តពេទ្យមធ្យម គិលានុប្បដ្ឋាក-យិកា។ សិក្ខាកាមស្ត្រីត្រូវបានលើកទឹកចិត្តអោយចូលរួម។

បើអស់លោក-លោកស្រីមានចំណាប់អារម្មណ៍សូមមេត្តាបំពេញបែបបទ និងឯកសារតម្រូវផ្សេងៗ យកមកដាក់នៅផ្នែកបណ្តុះបណ្តាលអេពីដេមីសាស្ត្រអនុវត្ត ( AET Office ) នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង បន្ទប់ជាន់ទីពីរអាគារថ្មី នៃក្រសួងសុខាភិបាល ឬដាក់ជូនលោកវេជ្ជបណ្ឌិត **លី សុវ៉ាន់** ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង(CDC) ឬតាមរយៈអ៊ីម៉ែល sovann_ly@online.com.kh និងចម្លងជូន (CC) មកអ៊ីម៉ែល aetcambodia@gmail.com ។

ការដាក់ពាក្យចាប់ផ្តើមពីថ្ងៃនេះតទៅការបរិច្ឆេទឈប់ទទួលពាក្យគឺនៅ**ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១៨**

ប្រសិនបើមានចម្ងល់លោក លោកស្រីអាចទំនាក់ទំនងមក៖

លោកវេជ្ជបណ្ឌិត **យី សេងដឿន** ទូរស័ព្ទៈ ០១៧ ៦៧០ ៩០៩ អ៊ីម៉ែលៈ **doeurn.cdc@gmail.com**

ឬលោកវេជ្ជបណ្ឌិត **ថៃ សាវុធ** ទូរស័ព្ទៈ ០១៦ ៧៦៦ ៧៥២ អ៊ីម៉ែលៈ **savuth.th@gmail.cambodia**

ឬលោក **គួច សុខដារ៉ាវិទ្ធិ** ទូរស័ព្ទៈ ០៧៧ ៩៩៥ ៥៤៣ អ៊ីម៉ែលៈ **aetcambodia@gmail.cambodia**

ឬ លោកស្រី **ជា សុបុណ្ណៈ** ទូរស័ព្ទៈ ០១២ ៧៧៣ ១៩៤ អ៊ីម៉ែលៈ cheas@wpro.who.int

ឬ លោកស្រី **យឹម ផារី** ទូរស័ព្ទៈ ០១១ ៥០៤ ៤៨៥ អ៊ីម៉ែលៈ **yimpharycdc@gmail.com** ។